**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈរដ្ឋមន្ត្រី**

ក្រសួងបរិស្ថាន

លេខៈ.........០៤៨៤...ប្រ.ក...........ប.ស្ត .កអច

រាជធានីភ្នំពេញ, ថ្ងៃទី.....១១.........ខែ..០៥........ឆ្នាំ២០០៤..

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "ត្នាតប៉ើយជឿនក្រសាំង" ភូមិត្នាតប៉ើយ ឃុំព្រីងធំ ស្រុកជាំក្សាន្ត ស្ថិតក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិ ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកប ១២៩៦/៣៦ ចុះថ្ងៃទី ២៤ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន
- បានឃើញសេចក្តីជូនដំណឹងលេខ ២៩៥ សជ ណ.កស ចុះថ្ងៃទី ១៦ ខែ មិនា ឆ្នាំ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្អែកតាមតំរូវការចាំបាច់របស់សហគមន៍មូលដ្ឋានដែលស្ថិតនៅក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព នៃភូមិត្នាតប៉ើយ ឃុំព្រីងធំ ស្រុកជាំ ក្សាន្ត ខេត្តព្រះវិហារ ។

## សំរេច

**ប្រការ១:**- រៀបចំសហគមន៍តំបន់ការពារធម្មជាតិដែលស្ថិតនៅក្នុងតំបន់ទ្រនាប់នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ក្នុងភូមិត្នាតប៉ើយ ឃុំព្រីងធំ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មានឈ្មោះថា "**សហគមន៍តំបន់ការពារធម្មជាតិត្នាតប៉ើយជឿនក្រសាំង**" ។

**ប្រការ២:**- សហគមន៍តំបន់ការពារធម្មជាតិត្នាតប៉ើយជឿនក្រសាំងនៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅភូមិត្នាតប៉ើយ ឃុំព្រីងធំ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ មានផ្ទៃដី **១.៧៦៣ហ.ត** ដូចបានកំណត់ក្នុងផែនទី ដែលមានអាប់ស៊ីស និងកូអ័រដោនេព្រំប្រទល់ដូចខាងក្រោម :

| ល.រ | កូអរដោនេ X | អាប់ស៊ីស Y | ល.រ | កូអរដោនេ X | អាប់ស៊ីស |
|---|---|---|---|---|---|
| B1 | 048 5956 | 1547276 | B11 | 0485591 | 1551988 |
| B2 | 0484451 | 1548537 | B12 | 0486664 | 1582215 |
| B3 | 0483201 | 1549516 | B13 | 0487460 | 1551943 |
| B4 | 0483270 | 1549936 | B14 | 0487695 | 1551408 |
| B5 | 0482767 | 1550912 | B15 | 0487337 | 1550855 |
| B6 | 0482620 | 1551202 | B16 | 0487463 | 1549992 |
| B7 | 0482808 | 1551784 | B17 | 0487505 | 1549182 |
| B8 | 0483266 | 1551779 | B18 | 0487461 | 1548239 |
| B9 | 0483739 | 1551829 | B19 | 0486974 | 1547749 |
| B10 | 0484555 | 1551833 | B20 | 0486460 | 1547271 |

**ប្រការ៣:**~ ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ នៃដែនជំរកសត្វព្រៃគូលែន-ព្រហ្មទេព និងការប្រើប្រាស់ធនធានធម្មជាតិ ក្នុងតំបន់នេះត្រូវចុះកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថាន ហើយសហគមន៍នេះត្រូវមានលក្ខន្តិកៈដោយឡែក ។

**ប្រការ៤:**~ អគ្គនាយកដ្ឋានបច្ចេកទេស  អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ បណ្ដានាយកដ្ឋានអង្គភាពពាក់ព័ន្ធ មន្ទីរបរិស្ថានខេត្តព្រះវិហារ និងសហគមន៍តំបន់ការពារធម្មជាតិត្នាតប៉ើយធឿនក្រសាំង នៃភូមិត្នាតប៉ើយ ឃុំព្រីងធំ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ចំលងជូន:*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- សាលាខេត្តព្រះវិហារ
- មន្ទីរបរិស្ថានខេត្តព្រះវិហារ
- ដូចប្រការ ៤ " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

រដ្ឋមន្ត្រី

ម៉ុក_ម៉ារ៉េត
បណ្ឌិត.ជីវវិទ្យា